# <u>តើ Providence ElderPlace PACE ជាអ្វី? (កម្មវិធីថែទាំសុខភាពសព្វបែបយ៉ាងសម្រាប់មនុស្សចាស់)?</u>

កម្មវិធីនេះផ្តល់ការថែទាំសុភាពនិងសេវាកម្មសព្វបែបយ៉ាងដែលរ៉ាប់រងដោយ Medicare និង Medicaid ដែលអនុញ្ញាតដោយក្រុមវេជ្ជបណ្ឌិត បុគ្គលិកសង្គមកិច្ច គ្រូពេទ្យ អ្នកជំនាញព្យាបាលរាងកាយនិងចលនា និងអ្នកជំនាញគ្លីនីកដទៃទៀតដែលពាក់ព័ន្ធនៅក្នុងការផ្តល់តំហែទាំសុខភាព។ មានផ្តល់ជូនការថែទាំនិងសេវាកម្មចាំបាច់ខាងវេជ្ជសាស្ត្របន្ថែមនិងសេវាផ្សេងៗដូចជាៈ ការថែទាំធ្មេញ/ធ្មេញសិប្បនិម្មិត សេវាព្យាបាលត្រចៀក ការព្យាបាលជើង ការព្យាបាលភ្នែក/ចក្ខុរោគ និងការផ្តល់ឱសថតាមវេជ្ជបញ្ជាដោយអ្នកផ្តល់សេវាថែទាំបឋមរបស់លោកអ្នក។

## <u>សេវាកម្ម PACE មានច្រើនដូចជាៈ</u>

- ការថែទាំសុខភាពបឋម
- សេវាជំនាញវេជ្ជសាស្ត្រ
- ការថែទាំសុខភាពតាមផ្ទះដោយគិលានុប្បដ្ឋាក
- ការថែទាំសុខភាពតាមផ្ទះ
- ការព្យាបាលរាងកាយ
- ទន្តសាស្ត្រ
- សេវាសង្គម
- ការដឹកជញ្ជូន
- ការថែទាំនៅមន្ទីរពេទ្យ
- ឱសថតាមវេជ្ជបញ្ជា
- សេវាសង្គ្រោះបន្ទាន់
- ការព្យាបាលតាមបែបលំហែកម្សាន្ត
- ការព្យាបាលដោលចលនា
- ការប្រឹក្សាអាហារូបបម
- សេវាមន្ទីរពិសោធន៍/អ៊ិុក្សរ៉េ
- តំហែទាំសុខភាពផ្លូវចិត្ត

**Providence ElderPlace** ផ្តល់មធ្យោបាយដឹកជញ្ជូនទៅមកពីមជ្ឈមណ្ឌល PACE សម្រាប់សកម្មភាពនានា ឬការណាត់ជួបគ្រូពេទ្យ។ ក៏មានផ្តល់ជូនផងដែរនូវការដឹកជញ្ជូនទៅជួបគ្រូពេទ្យតាមការណាត់ជួបនៅក្រៅមជ្ឈមណ្ឌល PACE។

**ការផ្តោតសំខាន់របស់ Providence ElderPlace PACE** គឺ ការថែទាំបង្ការដើម្បីជួយលោកអ្នកឲ្យរស់នៅក្នុងសហគមន៍មួយឲ្យបានយូរអង្វែងតាមដែលអាចធ្វើទៅបាន។

## <u>តើនរណាខ្លះអាចចូលរួមជាមួយ PACE?</u>

- លោកអ្នកដែលមានអាយុ 55 ឆ្នាំឬចាស់ជាងនេះ
- លោកអ្នកដែលរស់នៅក្នុងតំបន់សេវាកម្មនៃអង្គភាព PACE
- លោកអ្នកដែលត្រូវការសេវាគាំទ្រដូចដែលបានកំណត់ដោយរដ្ឋ Washington
- លោកអ្នកដែលអាចរស់នៅដោយសុវត្ថិភាពនៅក្នុងបរិស្ថានសហគមន៍

## <u>ទឹកប្រាក់ដែលលោកអ្នកត្រូវបង់ឲ្យ PACE អាស្រ័យទៅលើស្ថានភាពហិរញ្ញវត្ថុរបស់លោកអ្នក</u>

ប្រសិនបើលោកអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ Medicaid លោកអ្នកនឹងត្រូវបង់ប្រាក់ប្រចាំឆ្នាំ (ការចូលរួម) ឬក៏មិនបង់ទាល់តែសោះ។ ប្រសិនបើលោកអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ Medicaid ទេ គេនឹងគិតថ្លៃបុព្វលាភថេរប្រចាំខែពីលោកអ្នក។ អត្រាមិនប្រែប្រួលដោយផ្អែកលើតម្រូវការរបស់លោកអ្នក។

នឹងមិនមាន**ទឹកប្រាក់ត្រូវបង់មុននឹងក្រុមហ៊ុនធានារ៉ាប់រងបង់ជួស (Deductible) ឬទឹកប្រាក់ថេរដែលត្រូវបង់ (Copayment) សម្រាប់ថ្លៃឱសថ សេវាកម្ម បរិក្ខារពេទ្យដែលជាប់ធន់ ឬការថែទាំ** ដែលផ្តល់ជូនដោយក្រុម PACE។

ដើម្បីជ្រាបនូវព័ត៍មានបន្ថែម សូមទូរសព្ទទៅកាន់ Providence ElderPlace តាមលេខ

**206-320-5325 / 1-844-901-0094**

**TTY 1-800-855-2880**